THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
នាយក

ថ្ងៃទី 25 ខែកុម្ភៈ ឆ្នាំ 2021

សួស្តីគ្រួសារនៃមណ្ឌលសាលា Philadelphia ជាទីមេត្រី!

យើងមានសេចក្តីរីករាយ សូមជូនដំណឹងថា ដំណើរការផ្សះផ្សារបស់គតីយជន ដឹកនាំដោយទីក្រុង រវាងមណ្ឌលសាលា Philadelphia និងសហព័ន្ធគ្រូបង្រៀនទីក្រុង Philadelphia ស្តីពីដំណាក់កាលនៃការបើកសាលារៀនរដ្ឋនៅក្នុងទីក្រុងរបស់យើងឡើងវិញ កំពុងឈានដល់លទ្ធផលបញ្ចប់ហើយ។ សេចក្តីលម្អិតនឹងត្រូវសម្រេចចុងក្រោយក្នុងរយៈពេលប៉ុន្មានថ្ងៃទៀត ហើយនឹងត្រូវចែករំលែកប្រាប់ជូនអ្នកនៅថ្ងៃចន្ទ ទី 1 ខែមីនា ឆ្នាំ 2021។ ទន្ទឹមនឹងនេះ **សិស្សថ្នាក់មុនមតេយ្យដល់ថ្នាក់ទីពីររបស់យើង ដែលគ្រោងនឹងវិលមកសាលារៀនវិញនៅថ្ងៃចន្ទ ទី 1 ខែមីនា នឹងបន្តសិក្សាតាមប្រព័ន្ធឌីជីថលដដែល រហូតទាល់តែមានការផ្សាយពីសេចក្តីលម្អិតបន្ថែមទៀត។**

•

យើងដឹងថា ភាពមិនច្បាស់លាស់ជុំវិញការបើកអគារសាលារៀនយើងឡើងវិញប្រកបដោយសុវត្ថិភាព គឺជាក្តីបារម្ភ និងរឿងមិនសុខស្រួលចំពោះគ្រួសារជាច្រើន និងដឹងថា អ្នកចង់ដឹងអំពីសេចក្តីលម្អិតនៅថ្ងៃនេះ។ អ្វីដែលយើងអាចចែករំលែកបានថ្ងៃនេះ គឺនៅមានសេចក្តីលម្អិតសំខាន់មួយចំនួនកំពុងដោះស្រាយ ហើយយើងចង់សម្រេចចុងក្រោយលើសេចក្តីលម្អិតទាំងនោះ ដើម្បីយើងអាចប្រកាសនៅពេលតែមួយបាន អំពីផែនការទាំងមូលនៃការបើកឡើងវិញសម្រាប់សិស្សថ្នាក់ PreK-2 ដែលកំពុងរៀនសូត្រតាមប្រព័ន្ធឌីជីថល។

យើងបានផ្តោតលើ និងបន្តផ្តោតលើការបើកអគារសាលារៀនយើងឡើងវិញប្រកបដោយសុវត្ថិភាព ដើម្បីយើងអាចចាប់ផ្តើមផ្តល់ការបង្រៀនដោយផ្ទាល់ជាបណ្តើរៗ និងប្រកបដោយសុវត្ថិភាពជូនសិស្ស និងក្រុមគ្រួសាររបស់យើង ដែលចង់ និងត្រូវការជម្រើសសិក្សានេះ ដោយចាប់ផ្តើមដំបូងជាមួយសិស្សក្មេងរបស់យើង។

ខ្ញុំទន្ទឹមរង់ចាំចែករំលែកសេចក្តីលម្អិតនៅថ្ងៃចន្ទ។ សូមអរគុណចំពោះភាពអត់ធ្មត់ និងការយោគយល់របស់អ្នក ខណៈដែលយើងកំពុងបញ្ចប់ដំណើរការផ្សះផ្សារ ដើម្បីឧត្តមប្រយោជន៍របស់សិស្ស និងបុគ្គលិករបស់យើង។

ដោយសេចក្តីរាប់អាន!

William R. Hite Jr., Ed.D.
នាយក
មណ្ឌលសាលា Philadelphia